# ការសំភាសន៍របស់លោកពូ ជូហ័ត

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍មាន ពូ ជូ ហ័ត

<u>ការសង្ខេបប្រវត្តិរបស់លោកពូ ជូហ័ត</u>

លោកពូជូ ហ័ត មានអាយុ 54ឆ្នាំ នៅឆ្នាំ 2018 លោកពូ ជូហ័ត មានភេទ ប្រុស លោកពូ ជូហ័ត មានទីលំនៅបច្ចុប្បន្ន នៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ជាដំបូងខ្ញុំអរគុណពូដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ពូ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ពូ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឳពុកម្ដាយ នឹងដូនតាចឹងហាសពូ ហើយនៅពេលដែរខ្ញុំសំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambadianoralhistories.byu.edu ចឹងហាសពូ បាទចឹងពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ បាទដាក់ៗទៅមានអី។

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ពូគឺនៅថ្ងៃទី3 ខែ2 ឆ្នាំ2018 ហើយខ្ញុំនឹងសំភាសន៍ពូនៅទីកន្លែងភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ បាទពូ ចឹងសំរាប់ពូឈ្មោះពេញរបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ ខ្ញុំឈ្មោះហ័ត។

កៈ ឈ្មោះ ហ័តណាពូ ចុះមានត្រកូលអីទេពូ?

ខៈ ត្រកូលបើយើងដាក់ឳពុកឈ្មោះជូ ហ័ត។

កៈ ឈ្មោះ ជូ ហ័តណាពូ ចុះមានឈ្មោះ ហៅក្រៅទេពូ?

ខៈ គ្មានទេមានតែមួយនឹង។

កះ  អ៎ូ!មានតែមួយនឹងហោសពូ?

ខះ  បាទនឹងហើយ។

កះ  ចុះកាលពីតូចមានធ្លាប់មាននរណាហៅពូប្រើឈ្មោះអីផ្សេងទៀតទេពូ?

ខះ  គ្មានទេគ្មាននរណាហៅអីផ្សេងផងនឹង មានឈ្មោះតែមួយនឹង។

កះ  ចុះពូអាយុប៉ុន្មានដែរពូ?

ខះ  ខ្ញុំអាយុប្រហែលជា54ឆ្នាំហើយយ៉ាងនឹង។

កះ  អាយុ54ឆ្នាំណាពូ?

ខះ  បាទៗនឹងហើយ។

កះ  ចុះពូកើតនៅថ្ងៃខែឆ្នាំណាពូមានចងចាំទេ?

ខះ  គ្មានចាំទេតាំងពីយូរដែរហើយនឹង។

កះ  ចឹងពូកើតនៅឆ្នាំ1964ហាសពូ?

ខះ  បាទនឹងហើយ។

កះ  ចុះឆ្នាំច័ន្ទគតិពូមានដឹងថាពូកើតនៅឆ្នាំអីគេដែរទេពូ?

ខះ  ខ្ញុំហោស?

កះ  បាទដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះអីហាសពូ?

ខះ  ខ្ញុំឆ្នាំឆ្លូវ។

កះ  អ៎ូ!ពូឆ្នាំឆ្លូវហោសពូ?

ខះ  បាទឆ្នាំឆ្លូវនឹង។

កះ  ចឹងទីកន្លែងដែរពូកើតនឹងពូកើតនៅណាដែរពូ?

ខះ  ខ្ញុំកើតនៅខាងឃុំមហាលាភ ស្រុកកោះសូទិន។

កះ  ចុះភូមិអី ឃុំអីគេដែរពូ?

ខះ  ភូមិរដ្ឋមន្ទី ឃុំមហាលាភ។

កះ  អ៎ូ!នៅស្រុកកោះសូទិនណាពូ?

ខ៖ ស្រុកកោះសូទិន ខេត្តកំពង់ចាម។

ក៖ ចុះពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែរពូ?

ខ៖ ខ្ញុំបងប្អូនដូចជាភ្លេចអស់ហើយនេះ ខ្ញុំមានបងប្អូនចំនួន8នាក់ហោស។

ក៖ ពូមានបងប្អូនចំនួន8នាក់ហោសពូ?

ខ៖ បាទមាន8នាក់។

ក៖ ចុះពូមានស្រីប៉ុន្មាន នឹងប្រុសប៉ុន្មានដែរពូ?

ខ៖ មានស្រីតែ2នាក់ទេ។

ក៖ អូ៎!មានស្រីតែ2នាក់?

ខ៖ ប្រុសមាន6នាក់។

ក៖ ប្រុសមាន6នាក់ ចុះពូជាកូនទីប៉ុន្មានដែរទៅពូ?

ខ៖ ខ្ញុំជាកូនទី7ហោស។

ក៖ អូ៎!ជាកូនទី7ហោសពូ?

ខ៖ នឹងហើយបន្ទាប់ពៅនឹង។

ក៖ អូ៎!បន្ទាប់ពៅ ចុះពូមានចងចាំឈ្មោះបងៗរបស់ពូដែរទេពូ?

ខ៖ ចាំតាឈ្មោះពួកគាត់។

ក៖ បងគេមានឈ្មោះអីគេដែរទៅពូ?

ខ៖ បងគេមានឈ្មោះជន។

ក៖ អូ៎!ឈ្មោះជនណាពូ?

ខ៖ បងគេនឹងឈ្មោះជន បន្ទាប់មកស្រីឈ្មោះ ស្រ៊ុន។

ក៖ ឈ្មោះស្រ៊ុន ចុះទី3វិញពូ?

ខ៖ ទី3មានឈ្មោះ ប្រុសមានឈ្មោះប៉ោង។

ក៖ ចុះទី4វិញពូ?

ខ៖ ទី4វិញមានឈ្មោះបងវន។

កៈ បងវន ចុះទី5វិញពូ?

ខៈ ទី5នឹងស្រីឈ្មោះគឹមលី។

កៈ ចុះទី6វិញពូ?

ខៈ ទី6នឹងឈ្មោះអាញរ។

កៈ ឈ្មោះអាញរ ចុះអាញរនឹងស្រីរឺមួយក៏ប្រុស។

ខៈ វាប្រុសៗតា។

កៈ អូ៎!ប្រុសហោស ដល់ពេលដែរទី7ពូ?

ខៈ បាទដល់ពេលដែរទី8ឈ្មោះអាទូច។

កៈ ឈ្មោះទូចណាពូ?

ខៈ បាទអាទូច។

កៈ ប៉ុន្តែពួកគាត់មានគ្រួសារអស់នៅពូ?

ខៈ ពួកគាត់មានគ្រួសារអស់ហើយនឹង
កាលពីជំនាន់ពលពតគេចាប់តាំងអោយទៅធ្វើទាហ៊ានហើយស្លាប់អស់ពីរនាក់ហើយនឹង។

កៈ អូ៎!ចឹងហោសពូ?

ខៈ បាទស្លាប់មិនដឹងជាស្លាប់នៅណាដែរទេ។

កៈ ចឹងមានន័យថានៅតែ6នាក់ទេសពូថ្ងៃនឹង?

ខៈ នៅតែ6នាក់ប៉ុន្តែស្លាប់អស់2នាក់ទៀតហើយនឹង។

កៈ អូ៎!ស្លាប់អស់2នាក់ទៀតហើយចឹងមានន័យថាសល់តែ4នាក់ទេណាពូ?

ខៈ បាទនឹងហើយនៅសល់តែ4នាក់នឹង។

កៈ ចុះពូមានចងចាំថា កាលពីនៅក្មេងពូមានធ្លាប់លេងអីគេជាមួយបងប្អូនរបស់ពូទេពូ?

ខៈ កាលពីនៅក្មេងមានលេងអីទេ ចុះបើយើងនៅស្រុកស្រែចំការនឹង
ពួកគាត់ជាបងៗចឹងពួកគាត់ប្រើយើងអោយធ្វើការងារបន្តិចបន្តួចនឹងហាស។

កៈ អូ៎!បាទពូបាទ?

ខៈ យើងមានដែរលេងស្អីពីព្រោះតែគេជាបងរបស់យើងហើយនឹង។

កៈ ចុះពូមានធ្លាប់លេងលក្ខណៈគប់វង្ស គប់ឈូស លេងកៅស៊ូ លេងលោតអីទេពូ?

ខៈ អ៊ូ!អានឹង លេងតែចេះពីដើមគេលេងតែគប់ដាក់កៅស៊ូដាក់អីនឹងហាស។

កៈ ហើយយើងយកស្បែកជើងគប់ណាពូ?

ខៈ បាទយើងយកស្បែកជើងគប់នឹង។

កៈ ចុះបូមានលក្ខណៈថាលេងឡឹកបាយឡអីអត់ពូ
ជាមួយបងប្អូនរបស់ពូកាលពីនៅក្មេងៗហាសពូ?

ខៈ ទេធ្លាប់លេងដែរនឹងហាស។

កៈ អ៊ូ!ធ្លាប់លេដែរហោសពូ?

ខៈ បាទលេងជាមួយគ្នានឹងហាស។

កៈ លេងលក្ខណៈថាលេង រៀបការអីនឹងហោសពូ?

ខៈ ហេ៎!ខ្លះទៅ អត់ដែរលេងចឹងផង លេងតែឡឹកបាយឡលេងលក់
របៀបលេងលក់ដូរអីតិចតួចចឹងហាស។

កៈ លេងលក្ខណៈថាលេងឆាបាយលេងអីចឹងហោសពូ?

ខៈ បាទនឹងហើយ។

កៈ ចុះពូធ្លាប់មានទៅស្រែទៅដើរលេងអីជាមួយបងប្អូនរបស់ពូទេ?

ខៈ យើងនៅស្រុកស្រែចំការតែម្តងនឹង យើងនៅស្រុកចំការនឹង នៅជាប់ចំការនឹង
នៅចឹងទៅធ្វើចំការជាមួយម៉ែឪចឹងទៅណា។

កៈ អ៊ូ!ចឹងហោសពូ?

ខៈ នៅតូចៗតាមគាត់កាលពីនៅជំនាន់ពីដើមនឹង។

កៈ បាទពូបាទចឹង?

ខៈ នៅពេលដែរជំនាន់ពលពតមានបានដើរតាមគាត់អី។

កៈ អ៊ូ!បាទពូចុះពូចូលចិត្តលេងអីជាមួយបងប្អូនរបស់ពូ កាលពីនៅក្មេងៗហាសពូ
មិញនឹងពូធ្លាប់លេង តែនេះពូចូលចិត្តលេងជាមួយបងប្អូនរបស់ពូហាស?

ខ៖  មិនដឹងលេងអីផងនឹង មានតែប្រលែងគ្នានៅក្នុងផ្ទះអីចឹងទៅណា មិនសូវបានលេងអីជាមួយគ្នាផងនឹងហាស។

ក៖  អូ!បាទចឹងហោសពូ?

ខ៖  លេងតែប្រលែងគ្នាអីចឹងទៅអាលក្ខណះថាប្រលែងគ្នានឹងហាស។

ក៖  អូ!អាលក្ខណះថាលេងវៃគ្នាអីចឹងហោសពូ?
ខ៖  បាទប្រលែងគ្នាអីចឹងទៅ។

ក៖  លក្ខណះថាលេងបិទពួនអីចឹងហោសពូ?

ខ៖  បាទលេងចឹង។

ក៖  អូ!បាទពូ ចុះបងប្អូនរបស់ពូដែរគាត់នៅរស់ហាសឥឡូវនឹងពួកគាត់នៅណាដែរពូ?

ខ៖  គាត់នៅស្រុកហោស។

ក៖  នៅទាំងអស់គ្នាតែម្តងហោសពូ?

ខ៖  បាទៗគាត់នៅកំពង់ចាមនឹងហើយ។

ក៖  ចុះបងប្អូនរបស់ពូដូចជាពួកគាត់ធ្វើអីគេដែរពូ?

ខ៖  គាត់មានធ្វើអីទេ ពួកគាត់ធ្វើតែស្រែធ្វើចំការ ធ្វើប្រាំងអីដូចគ្នាចឹងហាស។

ក៖  អូ!ពួកគាត់3នាក់នៅធ្វើស្រែចំការនៅឯស្រុកទាំងអស់គ្នានឹង?

ខ៖  នៅស្រុកទាំងអស់គ្នានឹងហាស។

ក៖  អត់តែពូទេមកនៅភ្នំពេញហោសពូ?

ខ៖  ខ្ញុំគិតទៅមកនៅជិត2-3ឆ្នាំហើយដែរខ្ញុំអោយកូន មករៀននៅភ្នំពេញអីចឹងទៅណា។

ក៖  អូ!ចឹងទេហោសពូ?
ខ៖  បាទតែឥឡូវនឹងកូនៗនឹងគេមានគ្រួសារអស់ហើយនឹង។

ក៖  អូ!ចឹងពូមានចៅហើយណាពូ?

ខ៖  ខ្ញុំមានចៅដល់ទៅ4នាក់ហោស។

ក៖  អូ!ចឹងចៅមានច្រើនហាសណាពូ?

ខ៖  បាទនឹងហើយ។

កៈ ចុះម្ដាយរបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខៈ ម្ដាយរបស់ខ្ញូគេហៅតែយាយនាងៗនឹង។

កៈ អូ៎!ហៅយាយនាងៗ ចុះគាត់អាយុប៉ុន្មានដែរសព្វថ្ងៃនឹង?

ខៈ គាត់ស្លាប់យូរដែរហើយនឹង។

កៈ គាត់ស្លាប់ប្រហែលជាប៉ុន្មានឆ្នាំហើយពូ?

ខៈ កាពីគាត់ស្លាប់នឹងប្រហែលជាចិតមិនដល់ចិតផងមើលទៅ គាត់ដូចថាគ្មានឈឺអីផងនឹង។

កៈ អូ៎!ចឹងហោសពូ?

ខៈ
ដូចថាគាត់មកធ្វើការៗៗចឹងដល់ពេលដែរមកវិញទៅគាត់ក៏ដេកមួយថ្ងៃក៏បានស្លាប់បាត់ចឹងទៅណា អត់ដឹងមូលហេតុដែរ។

កៈ ប៉ុន្តែកាលពីគាត់ស្លាប់នឹងប្រហែលជាប៉ុន្មានឆ្នាំហើយពូ?

ខៈ ខ្ញុំមិនបានចាំទេកាលពីមុនខ្ញុំនឹងប្រហែលជា20ឆ្នាំជាងហើយនឹងហាស។

កៈ អូ៎!តាំងពី20ឆ្នាំជាងមកហោសពូ?

ខៈ នឹងហើយតាំងពីខ្ញុំអាយុ30ឆ្នាំជាងហើយនឹង។

កៈ តែឥឡូវនឹងពូអាយុ50ឆ្នាំជាងហើយណាពូ?

ខៈ បាទ54ឆ្នាំហើយនឹង។

កៈ ចុះពូមានដឹងថាម្ដាយរបស់បូគាត់កើតនៅណាដែរទេពូ?

ខៈ ស្រុកម្ដាយរបស់ខ្ញុំគាត់កើតនៅភូមិរដ្ឋមូន្នីតែម្ដងនឹង។

កៈ អូ៎!នៅភូមិរដ្ឋមូន្នីនឹងហោសពូ?

ខៈ បាទនៅណុង។

កៈ ចុះឪពុករបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខៈ គាត់មានឈ្មោះជូនឹង។

កៈ អ៎ូ!គាត់មានឈ្មោះជូហោសពូ?
ខៈ គាត់ឈ្មោះជូនឹង។

កៈ អ៎ូ!ចុះគាត់បានកើតនៅឆ្នាំណាដែរពូមានចងចាំទេ?

ខៈ មិនដឹងថាគាត់កើតនៅណាដែរទេនេះ
គាត់កូនកំព្រាដែរកាលពីដើមនឹងលឺតែគាត់ប្រាប់ទេណា។

កៈ បាទពូចឹង?

ខៈ គាត់ថាគាត់កំព្រាអត់ឪពុកម្ដាយ
ឪពុកម្ដាយរបស់គាត់បានស្លាប់ចោលអស់តាំងពីគាត់រស់នៅតូចៗម៉េសនឹង
ហើយមានប្អូនគាត់មួយនៅតូចជាងគាត់ទៀតអាយុប្រហែលជា3-
4ឆ្នាំចឹងហាសតូចជាងគាត់ទៀតនឹង។

កៈ បាទចឹងហោសពូ?

ខៈ អាយុប្រហែលជា5-6ឆ្នាំអីចឹងហាស គាត់និយាយថាគាត់ទៅនៅដល់វត្ត
គាត់បានបួសទាំងបងទាំងប្អូននឹងហាស។

កៈ អ៎ូ!គាត់បួសហោសពូ?
ខៈ លឺតែគាត់និយាយប្រាប់ទេ ចំណែកយើងអត់ដឹងទេនឹងហោស។

កៈ ចុះឪពុករបស់ពូគាត់កើតនៅណាពូមានដឹងទេ?

ខៈ គាត់កើតនៅស្រុកណុងដែរនឹង។

កៈ អ៎ូ!បាទពូចុះសំរាប់ឪពុករបស់ពូកាលពីគាត់នៅរស់គាត់ធ្វើអីគេសំរាបចិញ្ចឹមជីវិតដែរពូ?
ខៈ គាត់ទៅធ្វើចំការពីដើមនឹងគាត់ច្រើនតែទៅធ្វើចំការនឹង។

កៈ បាទពូនឹងហោសពូ?

ខៈ តែដល់ពេលឥឡូវនឹងគេមានស្រូវផងប្រាំងផងនឹងហាស។

កៈ គាត់ធ្វើតែចំការទេណពូ?

ខៈ បាទគាត់ធ្វើតែចំការទេ។

កៈ ចុះឪពុករបស់ពូគាត់ជាមនុស្សបែបណាដែរពូ គាត់ស្លូតរឺមួយក៏កាចដែរពូ?

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លូតដែរនឹងគាត់កាចតែជាមួយប្រពន្ធ
តែគាត់មិនដែរវៃតប់ជាមួយប្ដីប្រពន្ធគាត់ទេនឹងហាស។

ក៖ អូ៎!គាត់ស្លូតដែរហោសពូ?

ខ៖ គាត់គ្រាន់តែស្ដីមាត់ចឹងហាស តែគាត់ជាអ្នករកស៊ី។

ក៖ ចុះម្ដាយរបស់ពូគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខ៖ គាត់ធ្វើចំការជាមួយនឹងឪពុករបស់ខ្ញុំនឹង។

ក៖ អូ៎!ធ្វើជាមួយគ្នាហោសពូ?
ខ៖ បាទធ្វើចំការអីចឹងហាស។

ក៖ ចុះម្ដាយរបស់ពូគាត់ស្លូត រឺមួយក៏កាចដែរពូ?

ខ៖ ម៉ែរបស់ខ្ញុំគាត់ស្លូតហាស អ្នកស្រុកភូមិគេស្រលាញ់គ្រប់គ្នាហាស។

ក៖ អូគាត់ស្លូតហោសពូ?

ខ៖ ឪពុករបស់ខ្ញុំគាត់ក៏ស្លូតដែរ តែគាត់និយាយច្រើនបន្តិច។

ក៖ អូ៎!ពួកគាត់ស្លូតទាំងអស់គ្នា?

ខ៖ គ្រាន់ថាក្មេងៗមកសុំស្លឹកគ្រៃចឹងទៅគាត់ចេះតែជេរចឹងទៅ
ប៉ុន្តែអ្នកស្រុកមិនស្អប់គាត់ទេនឹងហាស គេមិនស្អប់គាត់ទេនឹង។

ក៖ ចឹងហោសពូ?

ខ៖ បាទគាត់គ្រាន់តែជេរលេងចឹងទៅណា។

ក៖ ចុះបូមានចងចាំសាច់រឿងណាដែរពូគិតថាពូមានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេ
ឪពុកម្ដាយរបស់ពូហាស?

ខ៖ គ្មានដែរធ្វើអីជាមួយពួកគាត់ទេនឹង។

ក៖ មានរឿងអីដែរពូចាំមិនភ្លេចទេ?

ខ៖ គ្មានធ្វើអីខុសផងនឹងជាមួយពួកគាត់នឹង។

ក៖ មិនមែនលក្ខណះថាធ្វើខុសទេ គ្រាន់តែថាលក្ខណះថាទៅធ្វើចំការជាមួយគ្នា
រឺក៏អនុស្សាវរីយ៍អីដែរសប្បាយជាមួយឪពុកម្ដាយរបស់ពូហាស។

ខ៖ នៅជាមួយកាត់យើងមានអីគ្រាន់តែយើងនៅតូចៗហើយតាមគាត់នឹង
គ្រាន់ថាគាត់ទៅចំការអីចឹងទៅ នឹងគាត់តៅដកសណ្ដែកដី
យើងទៅតាមគាត់ទៅដេកវាលចំការអីចឹងទៅណា។

ក៖ បាទចឹងហើយពូមានអីទៀតទេ?

ខ៖ ចុះយើងមានអីកាលណុងយើងនៅតូចៗដែរនឹង។

ក៖ លក្ខណះថាពូទៅលេងទឹករឺមួយក៏ទៅបេះផ្លែឈើអីចឹងហាសពូ
រឺពូមានដែរទៅដកបន្លែអីជាមួយគាត់ដែរទេពូ?

ខ៖ មានដែរតាគ្រាន់តែតាមមើលគាត់ទៅ
មើលបានបន្តិចចឹងយើងក៏មកផ្ទះវិញចឹងទៅណា នឹងកាលពីនៅក្មេងនឹងហាស។

ក៖
ចុះឪពុកម្ដាយរបស់បូគាត់មានធ្លាប់ប្រាប់ពីប្រវត្តិគាត់កាលពីនៅក្មេងរបស់ពូកគាត់ទៅពូទេ
នឹង?

ខ៖ គាត់មិនសូវនិយាយទេ តែឪពុករបស់ខ្ញុំគាត់និយាយខ្លះៗដែរនឹង ពីដើមមកគាត់កំព្រា
ម៉ែឪគាត់តាំងពីក្មេងមក។

ក៖ នឹងឪពុករបស់ពូ?

ខ៖ សំរាប់ម្ដាយរបស់ខ្ញុំនឹងខ្ញុំមិនសូវដឹងពីប្រវត្តិគាត់ទេនឹងហាស
គាត់មិនសូវនិយាយប្រាប់ទេ គាត់ភាគច្រើនគាត់និយាយប្រាប់គេអ្នកក្រៅ
ហើយខ្ញុំនៅក្បែរចឹងទៅខ្ញុំចេះតែលួចស្ដាប់ចឹងទៅណា។

ក៖ អូ៎!ចឹងហោសពូ?

ខ៖ គាត់គ្រាន់តែនិយាយថាគាត់កំព្រាថាគាត់មិនមានម៉ែឪទេ។

ក៖ ចុះយាយតាខាងឪពុករបស់ពូនឹងពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខ្ញុំដូចជាភ្លេចហើយនេះ ឪពុករបស់ខ្ញុំគាត់ហៅតែយាយឈួន
ឯខាងម្ដាយរបស់ខ្ញុំនឹងដូចជាកថាមិនចងចាំហាស។

ក៖ បាទពូចឹងហោសពូណ?

ខ៖ ចុះបើយើងកើតមកមិនទាន់ជីតាអីផងនឹងហាស។

ក៖ ចុះយាយតាខាងឪពុកពូមានចងចាំទេចឹង?

ខ៖ ធ្វើម៉េចចាំបើឪពុកពុកម្ដាយរបស់គាត់ស្លាប់តាំងពីគាត់នៅក្មេងមកម្ល៉េសនឹង។

ក៖ ចឹងពូអត់ស្គាល់ទេណពូ?

ខ៖ បាទមិនស្គាល់ទេ។

ក៖ ចុះគាត់កើតនៅឆ្នាំណាៗក៏ពូមិនដឹងដែរណពូ?

ខ៖ បាទមិនដឹងទេនឹងហាស។

ក៖ ចុះយាយតាខាងឪពុក នឹងយាយតាខាងម្ដាយគាត់កើតនៅណាពូមានដឹងទេពូ ឪពុកម្ដាយរបស់ពូគាត់ធ្លាប់ប្រាប់ទេនឹង?

ខ៖ គាត់កើតនៅស្រុកភូមិណុងឯងនឹង។

ក៖ ប៉ុន្តែនឹងខាងឪពុករឺ មួយក៏ខាងម្ដាយដែរពូ?

ខ៖ ទាំងខាងឪពុកនឹងខាងម្ដាយនៅណុងទាំងអស់គ្នានឹង នៅភូមិជាមួយគ្នានឹងឯងនឹង។

ក៖ អូ៎!បាទពូ ចុះពូមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅពូ ជាមួយក្រុមគ្រួសារហោស?

ខ៖ ខ្ញុំមកនៅជាងមួយឆ្នាំហើយនឹងហាស។

ក៖ មួយឆ្នាំជាងហោសពូ?

ខ៖ បាទមួយឆ្នាំជាងហើយនឹងហាស។

ក៖ ចឹងកាលពីមុននឹងពូទៅនៅស្រុក?

ខ៖ កាលពីមុននឹងខ្ញុំនៅស្រុកនឹង នៅភូមិរបស់ខ្ញុំនឹងនៅភូមិរដ្ឋមន្ទីនឹងឯងនឹង។

ក៖ ចឹងពូនៅស្រុកណុងរហូតណពូ?

ខ៖ បាទខ្ញុំនៅស្រុកណុងរហូតនឹងឯង

ក៖ អូ៎!បាទពូ ចុះពូមានសាច់ញាតិណាដែររស់នៅក្រៅប្រទេសទេពូ?

ខ៖ គ្មានទេ។

ក៖ អត់មានទេណពូ?

ខ៖ បាទគ្មានទេនឹងហាស។

ក៖ ចុះភរិយារបស់ពូគាត់មានឈ្មោះអីគេដែរទៅពូ?

ខ៖  គាត់មានឈ្មោះ ស៊ីម ។

ក៖  គាត់មានឈ្មោះ ស៊ីមណាពូ?

ខ៖  បាទឈ្មោះស៊ីមបាទ។

ក៖  អូ៎!ពូមានដឹងថា?

ខ៖  គាត់ឈ្មោះ សៅ ស៊ីមនឹង។

ក៖  ចុះពូមានចងចាំថ្ងៃខែឆ្នាំណាដែរពូបានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់ពូហាស?

ខ៖  ខ្ញុំគ្មានចាំឆ្នាំ ខែទេនេះ ប៉ុន្តែគ្រាន់តែខ្ញុំគ្មានការដូចគេសម័យឥឡូវនឹងហាស។

ក៖  ពូការនឹងពេលណាដែរ?

ខ៖  ខ្ញុំការនឹងនៅជំនាន់ពលតនឹង។

ក៖  អូ៎!ពូការជំនាន់ពលពតនឹងហោសពូ?

ខ៖  ពេលណុងអាពតវាចូលមកខេត្តកំពង់ចាមនឹងម៉ែឪការអោយកាលពីជំនាន់ណុងមានអីមានមាន់មួយ ទៅពីរនឹងមានអី។

ក៖  ប៉ុន្តែពេលណុងពូការនៅជំនាន់ពលពតណាពូ?

ខ៖  បាទការនៅពេលណុង។

ក៖  ប៉ុន្តែការនៅឆ្នាំណាដែរពូ នៅឆ្នាំចិតប៉ុន្មានដែរពូ?

ខ៖  យើងពីមុនសម្តេចហ៊ុនសែនវៃបែកនឹង។

ក៖  នៅឆ្នាំ1979រឺ1978?

ខ៖  នឹងហើយប្រហែលជាប៉ុនណុង គ្មានបានចាំទេ លែងតែគិតចាំអីបើម៉ែរបស់ខ្ញុំគាត់ខ្លាចខ្ញុំទៅណាទៅណីអីទៀតនឹង គាត់ក៏បានរៀបសែនអគីអោយចឹងទៅណា។

ក៖  អូ៎!ពូសែនចឹងទៅ?

ខ៖  នឹងហើយការជំនាន់ពលពតនឹងមានមាន់2-3អីចឹងទៅណា។

កៈ  អូ!ចឹងមានន័យថាពូការនឹងវាអស់ជាង40ឆ្នាំហើយណាពូ?

ខៈ  បាទការនឹងប្រហែលជា19ឆ្នាំ។

កៈ  ពូអត់ដល់20ឆ្នាំផងនឹង?

ខៈ  អត់ដល់20ឆ្នាំទេនឹងហាស។

កៈ  បាទអស់41ឆ្នាំហើយពូ?

ខៈ  នឹងហើយប៉ុណ្ណឹង។

កៈ  ចុះពេលដែរពូការនឹងតើពូជាអ្នករៀបចំអោយរឺមួយក៏
ឪពុកម្តាយរបស់ពូជាអ្នករៀបចំអោយដែរពូ?

ខៈ  ពុកម៉ែតាជាអ្នករៀបចំអោយនឹង។

កៈ  ចុះពេលដែរពូបានការជាមួយមីងនឹងដូចជាមានថ្លៃទឹកដោះទេពូ?
ខៈ  គ្មានទេ គ្មានអីទេកាលពីជំនាន់ណុងចាស់ៗគាត់លួចលាក់ដូចថាជាហ្វូល
រឺពីពលពតនឹងហោស គាត់ចេះតែនិយាយលេងទៅគ្មានតែផ្តាប់ទឹកដោះអីទេនឹងហាស។

កៈ  អូ!អត់មានទេណាពូ?

ខៈ  ចាស់ៗៗគាត់ត្រូវគ្នាចឹងហាស
ដល់ពេលដែរចូលស្ទួរចឹងទៅគេអោយទៅក៏រៀបការអីចឹងទៅណាស់។

កៈ  អូ!ចឹងហោសពូ?
ខៈ  ប៉ុន្តែការលួចលាក់ទេណាស់ លួចលាក់ពីអាពតកុំអោយអាពតដឹងនឹងហាស។

កៈ  ចុះពូអាចប្រាប់ខ្ញុំពីពេលដំបូងដែរពូបានជួបមីងនៅពេលណា
ហើយហេតុអីបានពូជួបមីង ដូចជាប្រវត្តិស្នេហាអីតិចបានទេពូ?

ខៈ  គ្មានទេ គ្មានស្នេហាអីទេនឹង ពីព្រោះតែខ្ញុំនៅស្រុកភូមិជាមួយគ្នានឹង ។

កៈ  អូ!បាទពូបាទ។

ខៈ  ខ្ញុំនៅស្រុករដ្ឋមូន្នី គេនៅស្រុករដ្ឋមូន្នីដូចតែគ្នានឹងហាស។

កៈ  ចុះពូបានស្គាល់មីងបានប៉ុន្មានខែបានពូចូលស្តីដណ្តឹងមីងចឹងហាស?

ខៈ  ខ្ញុំនៅជាមួយតាំងពីតូចៗមកម្លេសតែបែកគ្នាតាំងពីជំនាន់ពលពតនឹង
ដូចថាខ្ញុំទៅនៅខាងមេម៉ត់អីចឹងទៅណា។

កៈ អូ៎!ពូទៅនៅមេម៉ត់ហោសពូ?

ខៈ
នឹងហើយគេចាប់តាំងអោយទៅធ្វើការនៅរោងចក្រអីចឹងទៅណានៅស្រុកមេម៉ត់ហោស។

កៈ អូ៎!បាទពូបាទ?
ខៈ ទៅចាក់ជ័រទៅចាក់អីចឹងទៅណា។

កៈ បាទពូចាក់ជ័រណាពូ?

ខៈ បាទពេលដែរខ្ញុំមកវិញអីចឹងទៅណា នៅស្រុកភូមិជាមួយគ្នានឹង។

កៈ បាទពូ ចុះពូចេះអាន រឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរពូ?

ខៈ សរសេរមិនសល្អទេ បានត្រឹមតែមើលតែខ្លួនឯងនឹងហាស។

កៈ អូ៎!បានតែមើលខ្លួនឯងហោសពូ?

ខៈ បាទនឹងហើយ។

កៈ ចុះពូពេលណុងពូរៀនបានថ្នាក់ទីប៉ុន្មានដែរពូ?

ខៈ កាលណុងខ្ញុំរៀនបានតែថ្នាក់ទី4នឹង
ខ្ញុំកាលណុងខ្ញុំរៀនបានថ្នាក់ទី3នឹងគ្រូគេបានចាត់អោយខ្ញុំទៅធ្វើការនៅរោងចក្រ
នៅខាងតាប៉ាវហោស។

កៈ អូ៎!នៅតាប៉ាវ ប៉ូមទឹកនឹងហោសពូ?

ខៈ បាទតាប៉ាវយើងនៅស្រុកខាងខេត្តកំពង់ចាមនឹងហោស។

កៈ បាទនៅម្តុំខាងសួងណាពូ?

ខៈ បាទនៅខាងណុងម្តុំខាងរោងចក្រនឹងប៉ុន្តែធ្វើមិនទាន់បានរួចណាចិន
គេមកធ្វើចឹងដែរនឹងហាស។

កៈ បាទពូ ចុះកាលណុងពូរៀននឹង តើពូរៀននៅសាលាណាដែរពូ?

ខៈ ខ្ញុំរៀននៅសាលានៅភូមិមហាលាភនឹងហោស នៅវត្តតនះព្រីងនឹងហា។

កៈ អូ៎!ឈ្មោះសាលាឈ្មោះអីគេដែរទៅពូ?

ខៈ សាលាគេដាក់សាលាវត្តដំណាក់ព្រីងចឹងតែម្តងនឹងហាស។

កៈ នៅវត្តដំណាក់ព្រីងណាពូ?

ខៈ បាទឈ្មោះសាលាចឹង។

កៈ អ៎ូ!កាលណុងពូធ្លាប់មានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាដែរទេពូ?

ខៈ មានដែរមានអ្នកស្រុកអ្នកភូមិនៅជាមួយគ្នានឹងហាស
មានអ្នកស្រុកអ្នកភូមិដូចជាថាពួកម៉ាក់មិត្តភក្តិចឹងហាស។

កៈ អ៎ូ!មានមិត្តភក្តិដែរណាពូ?

ខៈ បាទដល់ពេលដែរដល់ជំនាន់ពលពតទៅក៏បែកគ្នាអស់ចឹងទៅណា
អាខ្លះក៏ស្លាប់បាត់ទៅ ហើយខ្លះទៀតក៏នៅរស់ចឹងទៅណា។

កៈ បាទពូ ចុះពូមានចងចាំឈ្មោះពួកគាត់ខ្លះដែរទេពូ?

ខៈ ចាំប៉ុន្តែទៅបាត់ទៅ ស្លាប់អស់ច្រើនដែរនឹងហាស។

កៈ ប៉ុន្តែពូអាចប្រាប់ឈ្មោះខ្លះៗដែរពូគិតថាពូចងចាំហាស?
ខៈ មានច្រើនហាសនៅស្រុកខ្ញុំហោសគេយកទៅវៃចោលតែម្តងនឹងហាស
ចឹងហាសគេយកទៅវៃចោលចឹងទៅបងជីដូនមួយរបស់ខ្ញុំនឹងមាន2នាក់។

កៈ អ៎ូ!បងប្អូនជីដូនមួយរបស់ពូបានស្លាប់ដែរ?

ខៈ មានអាឃាត អាធី អាយឿន អាហាម
អាខនអីនឹងច្រើនហាសនៅស្រុកខ្ញុំបានបាត់ច្រើនហាសនៅស្រុកខ្ញុំនឹង។

កៈ អ៎ូ!មានច្រើនហាសណាពូ?

ខៈ នឹងហើយខ្ញុំចង់ភ្លេចអស់ខ្លះដែរហើយនឹង បងៗរបស់ខ្ញុំនឹងហាស
ជីដូនមួយនឹងមានខ្មោចបងកុល ខ្មោចបងឈាវអីចឹងហាសបាត់ទៅអស់ហើយនឹង។

កៈ បាទពូចឹងហោស?
ខៈ កាលពីជំនាន់ពលពតនឹងអត់មានបានវិលមកវិញផងនឹង
ដូចជាបងរបស់ខ្ញុំអីចឹងទៅណា។

កៈ បាទចឹងស្លាប់ច្រើនណាពូ?

ខៈ បាទទៅធ្វើជាហ៊ានចឹងពលពតចាប់តាំងចឹងទៅគ្មានដឹងស្លាប់អីទេ
ហើយបានបាត់ឈឹងទាល់សព្វថ្ងៃចឹងទៅណា។

កៈ បាទពូ ចុះពូមានចងចាំអនុស្សាវរីយ៍អីកាលពូនៅជាមួយមិតត្តភក្តិរបស់ពូទេ?

ខៈ វាមានដែរតា ។

កៈ កាលពីនៅតូចៗហាសពូ?

ខៈ វាមានកាលពីតូចៗវាមានអីគ្រាន់តែវាមានតា កាលពីយើងនៅតូចៗចឹងយើងមិនទាន់បានចូលពលពតចឹងហាស យើងដើរលេងយប់ មានខែភ្លឺអីចឹងហាស មានលេងអ៊ូលេងអីចឹងហាស មានលេងខ្លូងលេងអីចឹងហាស។

កៈ អ៎ូ!ពេលណុងសប្បាយ?

ខៈ លេងអ៊ូអីចឹងហាស មានចាប់គ្នាទៅវិញទៅមកអីចឹងហាស ចឹងទៅលេងរត់ពួនលេងអីចឹងទៅណា។

កៈ ចុះពូមានលេងអីផ្សេងទៀតទេពូលក្ខណះថាអីចឹងហាស?

ខៈ ក្មេងៗពីដើមគេចូលចិត្តលេងអាជង្គង់អីចឹងហាស ។

កៈ លេងម៉េចវិញពូ?

ខៈ លេងអាជង្គង់គេថាជល់មាន់ៗហោសនឹងហាស គេចូលចិត្តលេងចឹងកាលពីជំនាន់របស់ខ្ញុំនឹងហោស។

កៈ ប៉ុន្តែគេលេងបិទពួនលេងអីដែរតាហីពូ?

ខៈ បាទគេលេង លេងពួនលេងអីចឹងទៅណា លេងអ៊ូអីចឹងទៅណា។
កៈ លេងគប់ឈូសលេងអីចឹងទៅណា?

ខៈ បាទទៅដូចថាមួយជំនាន់ៗហាស មួយសាររបស់ខ្ញុំគេលេងចឹងទៅ មួយសារបងៗរបស់ខ្ញុំគេលេងផ្សេងចឹងទៅណា គេលេងលាក់កន្លែងលេងអីចឹងទៅ គេមានរាំអីនៅក្នុងភូមិអីចឹងហាស។

កៈ បាទពូវាសប្បាយណាស់ពូ?

ខៈ បាទគេលេងរាំអីចឹងទៅណា។

កៈ បាទពូចឹងហោសពូ?

ខៈ បាទកាលណុងខ្ញុំនៅតូចៗដែរនឹង ហើយជំនាន់បងៗរបស់ខ្ញុំនឹងគេលេងរាំអីចឹងទៅណា។

កៈ បាទពូមានចេះភាសាអីក្រៅពីភាសាខ្មែរទេពូ?

ខៈ គ្មានចេះទេចេះតែខ្មែរមួយមុខនឹងហាស។

កៈ អូ៎!ចេះតែខ្មែរមួយទេណាពូ ចុះវៀតណាម ថៃ ឡាវ អីពូមិនចេះទេណាពូ?

ខៈ អត់ចេះទេ ប៉ុន្តែកាលពីខ្ញុំនៅកំពង់សោម កាលពីធ្វើការអោយវៀតណាមអីនឹង គេនិយាយមកអាចស្តាប់បានខ្លះៗ ប៉ុន្តែបើនិយាយទៅវិញស្តាប់អត់បានទេ។

កៈ អូ៎!ចឹងមានន័យថាពូចេះវៀតណាមខ្លះដែរៗណាពូ?

ខៈ អត់ចេះទេ គ្រាន់តែវានិយាយមកយើងស្តាប់បាន ហើយយើងនិយាយទៅវាក៏ស្តាប់បានដូចគ្នាដែរចឹងហាស ពីព្រោះទៅរកត្រីជាមួយគ្នាចឹងហាស។

កៈ ចុះពូធ្លាប់ទៅធ្វើការនៅវាលស្រែទេពូ?

ខៈ ខ្ញុំវាធ្វើស្រែ ធ្វើចំការវាតិចដែរនឹងហាស កាលពីជំនាន់ខ្ញុំនឹងកាលណុងខ្ញុំធ្វើស្រែធ្វើបឹងហាស កាលណុងខ្ញុំធ្លាប់ធ្វើដែរ។

កៈ ចុះពូធ្លាប់មានបង្កើតអាជីវកម្មទេ?

ខៈ មិនដែរផង ប៉ុន្តែធ្លាប់ធ្វើនេសាទ។

កៈ ពូធ្លាប់ធ្វើនេសាទណាពូ ចុះលក់ដូរអីពូធ្លាប់ធ្វើទេ?

ខៈ លក់ដូរមេនដែរធ្វើលក់អីគេទេ បើយើងលក់ត្រី លក់អីពេលនេសាទយើងលក់នឹងហោស លក់តែត្រីពេលដែរយើងនេសាទនឹងហាស។

កៈ បាទពូចឹងពូលក់ត្រី?

ខៈ បាទតែបើអោយលក់ទំនិញឥវ៉ាន់អីផ្សេងៗអត់ដែរលក់អីទេ។

កៈ ចុះពូធ្លាប់ចិញ្ចឹមសត្វទេដូចជាលក្ខណៈ មាន់ ទា ជ្រូក គោ ក្របីអីចឹងហាស។

ខៈ ធ្លាប់ចិញ្ចឹមដែរតា ខ្ញុំចិញ្ចឹមមាន់អីដែរពី ដើម ពុករបស់ខ្ញុំគាត់ចិញ្ចឹមគោអីដែរនឹង។

កៈ ប៉ុន្តែពូចិញ្ចឹមជាលក្ខណៈជាកសិដ្ឋាន រឺមួយក៏ចិញ្ចឹមជាគ្រួសារដែរពូ?

ខៈ អត់ទេចិញ្ចឹមជាលក្ខណៈគ្រួសារនឹង លក្ខណៈចិញ្ចឹមមាន2-3ៗអីចឹងទេ។

កៈ ចុះពូធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់ពូដែរ?

ខ៖ ខ្ញុំកាលណុងគ្មានធ្វើការងារអីគេទេ យើងធ្វើនៅជំនាន់ពលពតធ្វើរោងចក្រ ពេលដែរពលពតតាមទៅដល់នឹងយើងក៏រត់ចូលព្រៃរហូតនឹង។

ក៖ ចុះពូគិតថាជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះដែរពូ កាលពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ឥឡូវនឹងវាផ្លាស់ប្តូរច្រើនហាស ពីមុនយើងមានអីយើងស៊ីបាយសហករគេនឹងហាស តែឥឡូវនឹងយើងមានបាយឯកជនស្រេចចិត្តនឹង។

ក៖ បាទនេះជាការផ្លាស់ប្តូររបស់ពូ ចុះជីវភាព រឺមួយក៏សុខភាពអីយ៉ាងម៉េចដែរពូ?

ខ៖ អត់អីទេខ្ញុំដូចជាមិនសូវជាឈឺអីដែរនឹង ចំពោះខ្ញុំវាមិនសូវជាឈឺអីទេ។

ក៖ ពុំន្តែជីវភាពវិញពូ អត់អីទេល្អតាហីពូ?

ខ៖ បាទជីវភាពយើងបើនិយាយថាចាស់ៗពីដើមនឹង ដូចថាចាស់ៗពីដើមនឹងសួរតែម៉ែឪរបស់ខ្លួនឯងនឹងដឹងទៅហើយ។

ក៖ ចុះម្ហូបអីគេដែរពូចូលចិត្តពិសារជាងគេដែរពូ?

ខ៖ ខ្ញុំសាមញ្ញស្អីក៏ខ្ញុំហូបដែរនឹងគ្មានរើសទេ។

ក៖ លក្ខណះម្ហូរ សៀ ឆា ការី កកូរអីចឹងហាស?

ខ៖ ស្អីក៏ខ្ញុំហូបដែរនឹង។

ក៖ ពូស្អីក៏ហូបប៉ុន្តែម្ហូបអីគេដែរពូគិតថាពេលដែរគិតក៏នឹកឃើញថាចង់ហូបចឹងហាស?

ខ៖ បើនិយាយពីចូលចិត្តវិញនឹង ដូចជាស្លម្ហូរគ្រឿងអីនឹងចូលចិត្ត។

ក៖ អូ៎!ចឹងហោសពូ ស្លម្ហូរគ្រឿងសាច់គោណពូ?

ខ៖ ទេស្លម្ហូរគ្រឿងសាច់គោ នឹងសាច់ត្រីនឹងចូលចិត្ត។

ក៖ ចុះល្បែងប្រជាប្រិយ៍អីដែរពូគិតថាពូចូលចិត្តលេងជាងគេហាស ដូចជាល្បែងចោលឈូង បោះអង្គុញ ទាញព្រាត អីចឹងហាសពូ?

ខ៖ ដូចជាមិនសូវជាបានលេងអីដែរខ្ញុំ ដល់ពេលដែរមានប្រពន្ធចឹងទៅ ដូចជាមិនសូវជាបានលេងទេមើលតែក្មេងៗលេងនឹង គ្រាន់តែក្មេងវារៃលុយតាមអ្នកស្រុកអ្នកភូមិនឹង ។

ក៖ អូ៎!រៃលុយគ្នាចឹងទៅ?

ខ៖ នឹងហើយដូចថាមួយគ្រួសារ5000រៀលអីចឹងហាស រឺ10000រៀល រឺក៏15000រៀលអីចឹងទៅណា តែដល់ពេលដែរក្មេងសម័យឥឡូវនឹងដូចថាដល់ខែបុណ្យទាន ចូលឆ្នាំអីចឹងទៅនាំគ្នារៃលុយគ្នាដាក់បាសរាំនៅក្នុងស្រុកអីចឹងទៅណា។

ក៖ អូ្ន!ចឹងសប្បាយណាស់ពូ?

ខ៖ នឹងហើយមួយភូមិនឹងរាំទាំងចាស់ រាំទាំងក្មេងអីចឹងទៅណា ហើយនរណាគេមិនរាំក៏អត់ទៅណា។

ក៖ ប៉ុន្តែកាលពីនៅក្មេងពូលេងណាពូ?

ខ៖ បាទលេងដែរនឹង ទៅរាំអីនឹងគេដែរនឹងហាស។

ក៖ ចុះពូគិតថាមានចំរៀងណាដែរពូគិតថាពូរៀនច្រៀងតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូនៅតែចាំចឹងហាស?

ខ៖ អូ្ន!ភ្លេចអស់ហើយនឹងហាស ច្រៀងវាមិនចាំប៉ុន្មានទេគ្រាន់តែថា ច្រៀងចាំមួយម៉ាត់ពីរម៉ាត់អីចឹងហាសគ្មានចេះអីទេ។

ក៖ ចុះពូចូលចិត្តស្តាប់បទចំរៀង បទសម័យរឺក៏បទបុរាណដែរពូ?

ខ៖ បទស្អីលក្ខណះថាបទខ្មែរលើ ខ្មែរអីចឹងទៅដូចថាអ្នកច្រៀងពិរោះខ្ញុំស្តាប់ដែរនឹងហាស។

ក៖ ចុះពូមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់ពូចេះលេងឧបករណ៍ភ្លេងទេពូ?

ខ៖ គ្មានទេអត់ចេះទេ។

ក៖ បងប្អូនជីដូនមួយអីអត់ចេះដែរ?

ខ៖ អត់ចេះទេលេងទេនឹង។

ក៖ ចុះផ្ទះរបស់ពូមានលក្ខណះបែបណាដែរពូតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូកាលពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចដែរចឹងទៅណាពូ?

ខ៖ ពីដើមយើងនៅជាមួយគ្រួសារ នៅជាមួយឪពុកម្តាយ ដល់ពេលឥឡូវនឹងយើងវាមានផ្ទះមានសំបែងខ្លួនយើងនឹង ដូចថាអ្នកស្រុកអ្នកភូមិនឹងវាមិនក្រោមគេចឹងហាស។

កៈ  បាទពូ ចុះនរណាគេជាអ្នកសាងសងផ្ទះរបស់ពូមួយនឹងដែរពូ?

ខៈ  ផ្ទះនឹងខ្ញុំជាអ្នកសាងសងដោយខ្លួនឯង ប៉ុន្តែយើងជួលជាងហាស។

កៈ  អូ៎!យើងជួលជាងជាអ្នកធ្វើអោយហោសពូ?

ខៈ  លុយកាក់លើយើង យើងគ្រាន់តែជួលជាងធ្វើអោយនឹងហាស។

កៈ  ចុះផ្ទះរបស់ពូនឹង ពូគិតថាគេប្រើឧបករណ៍អីសំរាស់សាងសងផ្ទះរបស់ពូទេ?

ខៈ  ជាងឥឡូវនឹងវាមានតែម៉ាស៊ីនឈូស រណាអីចឹងទៅ ឈូសអីចឹងទៅណា។

កៈ  អូ៎!បាទពូត្រូវហើយ?

ខៈ  ប៉ុន្តែឥឡូវនឹងគេច្រើនតែប្រើម៉ាស៊ីនម៉ូទ័រ ខ្សែភ្លើងនឹង វាលឿន ។

កៈ  ចុះពូគិតថាសព្វថ្ងៃនឹងជំនាញអីដែរពូចេះស្ទាត់ជំនាញហាសពូ
ដែរពូអាចធ្វើវាបានហើយស្ទាត់ជំនាញហាស?

ខៈ  អ្វីដែរខ្ញុំចេះស្ទាត់នឹងគ្មានអីគេទេ យើងនៅស្រុកស្រែចំការនឹង បើនិយាយអោយចំទៅ
យើងចេះតែធ្វើលប ធ្វើទ្រូនឹងហាស។

កៈ  អូ៎!បាទពូ អានឹងពូស្ទាត់ហាសណពូ?

ខៈ  បាទចេះធ្វើចឹង គ្មានចេះអីក្រៅពីនឹងទេ អ្នកស្រែចំការអ្នករកត្រីនឹង

កៈ  ចុះម្តាយឳពុករបស់ពូមានធ្លាប់បានបង្រៀនពីជំនាញអីទៅពូទេ
ដូចជាលក្ខណៈថាវេញរល្លី ធ្វើផ្តៅ រឺធ្វើល្អីអីចឹងហាសពូចេះទេ?

ខៈ  អត់ដែរផង គាត់មិនដែរផងនឹងមិនដែរបានបង្រៀនទេ។

កៈ  អូ៎!ចឹងពូមិនដែរទេចេះទេ?

ខៈ  បាទពីព្រោះអីខាងស្រុកខ្ញុំគេធ្វើតែចឹងហាស ខ្លះគេធ្វើតុំទៅ ខ្លះគេធ្វើទ្រូ
ខ្លះគេធ្វើលបចឹងទៅណាសំរាប់ដាក់ខែវស្សាចឹងទៅណា។

កៈ  អូ៎!បាទល្អតាពូ?

ខៈ  ពីព្រោះយើងស្រុកចំការ ស្រុកទន្លេអីចឹងហាស។

កៈ  ចឹងមានន័យថាពូស្ទាត់ជំនាញជាងគេធ្វើតុំ ធ្វើលបអីចឹងហាសណពូ?

ខៈ  បាទជំនាញរបស់ខ្ញុំនឹង។

ក៖
ចុះពូអាចប្រាប់ខ្ញុំបានទេថាពេលណាដែរពូគិតថាជាពេលដែរលំបាកនៅក្នុងជីវិតរបស់ពូហាស តាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ លំបាកជាងគេនឹងមានតែជំនាន់ពលពតនឹងដែរពិបាកនឹងហើយ ពីព្រោះតែយើងមកដល់ផ្ទះហើយមិនបានដេកផ្ទះផងនឹង។

ក៖ ពូអត់ដែរបានដេកផ្ទះទេ?

ខ៖ បាទខ្ញុំដេកតែក្នុងព្រៃនឹង ដេកកាលពីជំនាន់ពលពតនឹងហាស។

ក៖ អូ៎!ពូពេលណុងគេអោយជំលាសទៅណាដែរទៅពូ?

ខ៖ កាលណុងខ្ញុំមានប្រពន្ធហើយ ចឹងគេជំលាសអោយទៅដល់ស្រុកសណ្តាន់ស្ទួងនឹង។

ក៖ នៅខាងកំពង់ធំណាពូ?

ខ៖ បាទស្រុកសណ្តាន់នៅកំពង់ធំនឹងគេបានជំលាស់ទៅដល់ណុង កាលណុងគេជំលាសទៅដល់ណុងហើយមានគុម្ពឬស្សីនឹង ដល់ពេលណុងគេចសុទ្ធតែរណ្តៅបេ៊។

ក៖ ពេលដែរពូរត់?

ខ៖ នឹងហើយរណ្តៅបេ៊ជ្រៅៗហាស?

ក៖ ចុះគេអោយពូធ្វើអីគេដែរទៅពូ?

ខ៖ គេជំលាសទៅដូចជាគ្មានបានធ្វើអីផងនឹង គ្រាន់តែជំលាសទៅដល់ណុងចឹងហាស គេចាត់ទៅអោយទៅភូមិណា នៅភូមិណីគេមិនទាន់អោយធ្វើអីផងនឹងហាស គេយកយើងទៅដាក់ក្នុងព្រៃនឹងហាស មិនមែនដាក់ក្នុងភូមិណា។

ក៖ ចឹងប៉ុន្មាន2-3ឆ្នាំពូនៅក្នុងព្រៃរហូតទៅ?

ខ៖ វាមិនដល់2-3ឆ្នាំទេ ជំលាសទៅឆាប់ដែរនឹង ដូចថាពីជំនាន់ណុងយើងតស៊ូទៅ ហើយក៏វៀតណាមវៃចូលទៅ។

ក៖ បាទពូបាទ?

ខ៖ អត់ទាន់បានមួយឆ្នាំផងនឹង។

ក៖ ចុះដូចជាពូឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរពូ?

ខ៖ វាគ្រាន់តែយើងពិបាកពេលដែរគេជំលាសយើងទៅនឹង វែកមានរបស់ស៊ី
ខោអាវអីចឹងទៅណាយើងវែកដើរចុះកាលពីជំនាន់ណុងគ្មានម៉ូតូ
កង់ដូចគេជិះសព្វថ្ងៃណា។

ក៖ បាទពូត្រូវហើយគ្មានអីជិះទេ?

ខ៖ នឹងហើយកាលពីជំនាន់ដើរ វែកបានប៉ុណ្ណាយកបានប៉ុណ្ណឹងឯង។

ក៖
ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ពូហា
ស ដែរគិតថាសប្បាយចឹងហាស?

ខ៖ សប្បាយវាគិតថាឥឡូវនឹងហាស
ដូចថាពេលដែរយើងសប្បាយពេលដែរបានជួបជុំមិត្តភក្តិម្តង មួយយាមអីចឹងទៅណា។

ក៖ អ៊ូ!មានអីសប្បាយទៀតទេ?

ខ៖ ដូចថាសប្បាយពេលដែរទៅលេងអ្នកផ្ទះ
បងប្អូនរបស់អ្នកស្រុកអ្នកភូមិអីចឹងទៅសប្បាយហើយ សព្វថ្ងៃនឹងវាធម្មតានឹង។

ក៖ ចុះពូគិតថាពេលដែរពូការកូន រឺមួយក៏ពូការខ្លួនឯងដែរធ្វើអោយពូសប្បាយហាសពូ?

ខ៖ ហ៎!ការកូននឹងក៏ខ្ញុំសប្បាយដែរនឹងហាស។

ក៖ ប៉ុន្តែហាត់ណាពូ?

ខ៖ គ្មានហាតអីទេជួលតែចុងភៅគេធ្វើនឹងហាស។

ក៖ អ៊ូ!ពូជួលគេអោយធ្វើណាពូ?

ខ៖ បាទជួលគេនឹង។

ក៖ ចុះកាលពីនៅក្មេងហាស
ពូមានធ្លាប់មានក្តីស្រម៉ៃថាពូពេលដែរធំឡើងពូចង់ធ្វើអីគេដែរទេពូ?

ខ៖ ខ្ញុំគ្មានស្រម៉ៃអីគេដែរនឹងហាស
កាលពីជំនាន់ណុងកាលពីជំនាន់ពលពតនឹងយើងនៅក្មេងៗដែរនឹងហាស
បានអីមានការស្រម៉ៃ ម៉ែឪលំបាកកាលពីជំនាន់ណុងមានអីស្រម៉ៃ។

ក៖ បាទពូបាទ។

ខ៖ ចុះយើងនៅក្មេងៗនឹងយើងមានស្រមៃណា?

ក៖ ចុះបើចង់អោយពូផ្ដែផ្ដាំទៅក្មេងជំនាន់ក្រោយហាស
តើពូចង់ផ្ដែផ្ដាំអីទៅកូនចៅជំនាន់ក្រោយៗហាសពូ?

ខ៖
ដូចជាមិនដឹងថាផ្ដែផ្ដាំអីទេពីព្រោះក្មេងសម័យឥឡូវនឹងវាចេះជាងយើងផងនឹងហាស។

ក៖ ចុះបើពូគិតថាពូចង់និយាយទូន្មានអី
រឺមួយចង់ផ្ដែផ្ដាំអោយពួកគាត់ធ្វើម៉េចល្អចឹងហាសពូ?

ខ៖ យើងធ្វើម៉េចល្អបើសម័យឥឡូវនឹង
ក្មេងសម័យឥឡូវនឹងវាចេះជាងចាស់ៗកាលពីខ្ញុំនៅជំនាន់មុនផងនឹងហាស។

ក៖ បាទពូត្រូវហើយ។

ខ៖ បាទខ្លះទៅវាខឹល ខ្លះទៅវាខូចអីចឹងទៅណា ប៉ុន្តែភាគច្រើនវាល្អច្រើនហាស

ក៖ បាទនឹងហើយពូ?

ខ៖ ក្មេងសម័យឥឡូវនឹងគេបានរៀនជ្រៅជ្រះហាស។

ក៖ បាទពូបាទត្រូវហើយនឹង។

ខ៖
មិនមែនកាលដូចជាជំនាន់ខ្ញុំនៅពលពតនឹងរៀនមិនបានជ្រៅជ្រះហើយក្មេងដូចជាមិនសូវ
ដឹងទេ។

ក៖ បាទពូមានអីផ្សេងទៀតទេពូ?

ខ៖ បាទគ្មានទេនឹង។

ក៖ អូ៎!បាទពូ
ចឹងជាចុងក្រោយខ្ញុំអរគុណពូដែរបានអោយខ្ញុំបានពិភាក្សាជាមួយពូដែរទាក់ទង់ទៅនឹងប្រវ
ត្តិរបស់ពូហាសពូ?

ខ៖ បាទនឹងហើយ។

ក៖ បាទខ្ញុំអរគុណច្រើនពូ៕៕៕